## បទបញ្ញត្តិប្រតិបត្តិលេខ #SPU – DR-01-08

## ការដាក់ធុងសំរាម, សំណល់ផលិតឡើងវិញនិងធុងសំណល់អាចធ្វើជី និងស្បោងសំរាមបណ្តោះអាសន្ន ហើយនិងការយកចេញពីចិញ្ចើមថ្នល់ និងច្រកផ្លូវសាធារណៈ

### អត្ថបទសំណើនៃបទបញ្ញត្តិៈ

**1.0 បុព្វកថាៈ**
បទបញ្ញត្តិ SMC ជំពូក 15.04.010 តំរូវឲ្យមានការអនុញ្ញាតសំរាប់ជនម្នាក់ៗ "ប្រើ" បានយូរអង្វែងនូវកន្លែងសាធរណៈដែលជាច្រកផ្លូវ, វុក្ខវិថីថ្មើជើង ឬចិញ្ចើមថ្នល់សំរាប់ថ្មើជើង។ ទោះបីយ៉ាងណាក៏ដោយ ការ"ប្រើ" កន្លែងសាធារណៈក៏អនុញ្ញាតឲ្យមានកន្លែងបណ្តោះអាសន្នសំរាប់អតិថិជនឲ្យដាក់តាមចញ្ចើមថ្នល់./ច្រកផ្លូវ នូវសំរាមនិងសំណល់ផលិតឡើងវិញសំរាប់ឲ្យប្រមូល នោះគឺនៅក្នុងការអនុវត្តតាមបទបញ្ញត្តិ SMC 21.36.080 ។ បទបញ្ញត្តិ SMC ជំពូក 21.36.080 B អនុញ្ញាតឲ្យដាក់ធុងនៅតាមចញ្ចើមថ្នល់ថ្មើជើងឬនៅតាមច្រកផ្លូវឬតាមវុក្ខវិថីថ្មើជើង ដរាបណាដែលការដាក់ទាំងអស់នោះ "សមហេតុផលនៃពេលវេលានៅមុនពេលប្រមូលយក" ហើយនិងយកទៅវិញ "នៅក្នុងរយៈកំឡុងពេលសមហេតុផលតាមការនោះ"។

ធុងទាំងនោះមានរួមទាំងស្បោងស្មៅ, ធុងសំរាមចំណុះ 12, 20 និង 32 ក្លាឡុង, ធុងរទេះចំណុះ 32 – 96 ក្លាឡុង ហើយនិងទូរសំរាមធុងរទេះ មានចម្ងាយពីមួយទៅមួយ 20 យ៉ាតពីគ្នា ដែលប្រើសំរាប់ប្រមូលសំរាម, សម្ភារៈផលិតឡើងវិញ ឬសំណល់ធម្មជាតិ(សំណល់ស្មៅនិងអាហារ) ដោយពលរដ្ឋឬហាងពាណិជ្ជកម្ម។ រយៈពេលសមហេតុផលនៅមុនពេលនិងនៅក្រោយពេលប្រមូល ដែលកំណត់នៅក្នុងបទបញ្ញត្តិនេះ មិនមែនជាប់ទាក់ទងគ្រប់សេវាដែលមានកុងត្រាជាមួយសាលាក្រុងទាំងអស់ទេសំរាប់សំរាម, សម្ភារៈផលិតឡើងវិញនិងសំណល់អាចធ្វើជី(សំណល់ស្មៅនិង អាហារ) ប៉ុន្តែក៏មានសេវាដែលគ្មានកុងត្រា, សេវាប្រមូលឯកជនផងដែរ។ គឺមិនអនុវត្តចំពោះកន្លែងដាក់ឲ្យធុងសំរាមនៅទីសាធារណៈ ដែលជាផ្លូវឲ្យប្រើប្រាស់ត្រូវបានទទួលការអនុញ្ញាតពីសាលាក្រុងនោះទេ។

**2.0 រយៈកំឡុងពេល "សមហេតុផល"នៃការដាក់និងយកធុងសំរាមមកវិញនៅមុនពេលនិងក្រោយពេលប្រមូលនៅតាមចិញ្ចើមថ្នល់និងច្រកផ្លូវ សាធារណៈ**

**ធុង, ធុងរទេះឬទូររទេះសំរាមៈ** ធុង, ធុងរទេះឬទូររទេះសំរាមរបស់ពលរដ្ឋ និងរបស់ពាពាណិជ្ជកម្ម (ឬទូរសំរាម) មានដាក់សំរាម, សំណល់ផលិតឡើងវិញឬអាចធ្វើជីបានអាចដាក់បណ្តោះអាសន្នបាននៅលើចិញ្ចើមថ្នល់, នៅលើវុក្ខវិថីវងឬនៅលើច្រកផ្លូវសាធារណៈរហូតដល់ទៅ 24 ម៉ោង មុនពេលដែលប្រមូលយកដោយអ្នកមានកុងត្រាជាមួយទីក្រុង។ ធុងទាំងនោះគួរត្រូវអតិថិជនយកទៅវិញហើយទុកដាក់វាទៅតាមកន្លែងដើមដោយត្រឹមត្រូវនៅក្នុង រយៈពេល 24 ម៉ោងក្រោយពេលដែលគេបានប្រមូលសំរាមរួចហើយ។ ធុងស្មៅចោលក៏ត្រូវយកទៅក្នុងរយៈពេល 24 ម៉ោងនៅមុនពេលដែលគេមក ប្រមូលយកដែរ។ ទោះបីយ៉ាងណាក៏ដោយ សំរាមលើសដែលច្រកស្បោងដាក់នៅខាងក្រៅធុង, ធុងរទេះឬទូររទេះសំរាមសំរាប់ឲ្យគេប្រមូលយកដូចសំរាមដែរនោះ អាចដាក់នៅតាមចិញ្ចើមថ្នល់, នៅវុក្ខវិថីថ្មើជើងឬតាមច្រកផ្លូវបានតែ 3 ម៉ោងនៅមុនពេលគេមកប្រមូលប៉ុណ្ណោះ បើសិនជាស្បោង សំរាមនោះមានរបស់ធុំក្លិនស្អុយអាក្រក់។ វាអាចដាក់នៅពេលល្ងាចមុនពេលមកប្រមូល បើសិនជាស្បោងសំរាមនោះគ្មានធុំក្លិនស្អុយអាក្រក់។

គឺគ្មានកន្លែងដាក់ធុង, ធុងរទេះឬទូររទេះសំរាមឲ្យនៅជាអចិន្ត្រៃយ៏លើចិញ្ចើមថ្នល់ថ្មើជើង, វុក្ខវិថីថ្មើជើងឬច្រកផ្លូវសាធារណៈនោះទេ លើកលែងតែម្ចាស់កម្មសិទ្ធិគ្មានកន្លែងសំរាប់ដាក់ទូររទេះសំរាមនៅកន្លែងកម្មសិទ្ធិរបស់គេឬនៅក្នុងអាគាររបស់គេ។ នៅពេលនោះទូររទេះអាចត្រូវទុកចោលនៅតាមច្រកផ្លូវ សាធារណៈ ដរាបណាគេរក្សាការបិទគំរបឲ្យជិត, ជុំវិញទូររទេះត្រូវរក្សាការស្អាតជានិច្ច ហើយនិងទូររទេះទាំងនោះគ្មានការរំខានជាមួយនឹងអ្នកថ្មើជើងឬចរាចររថយន្តចេញចូលនឹងប្រើប្រាស់។ នាយកចាត់តាំងនៃ SPU អាចផ្សៀងនូវកង្វះខាតនៃទីកន្លែងសំរាប់ដាក់ធុងនៅក្រៅពីកន្លែង ROW ។

**3.0 កម្មវិធី "ច្រកផ្លូវស្រឡះ"ៈ** ច្រកផ្លូវសាធារណៈនៅ Downtown និងនៅមូលដ្ឋានមណ្ឌលពាណិជ្ជកម្មមានទូរទេះធំមាចាក់សំរាមជាអចិន្ត្រៃយ៏ ដែលផ្តល់គំរបសំរាប់គ្រប កុំឱយមានភាពមិនត្រឹមត្រូវនឹងខុសច្បាប់,

រារាំងអ្នកថ្មើជើងនិងចរាចរណ៍រថយន្តប្រើប្រាស់ ហើយនិងទាញអារម្មណ៍ដល់ ការចោលសំរាមខុសច្បាប់។ អតិថិជនពាណិជ្ជកម្មជាច្រើននៅក្នុងកម្មវិធីពិសោធន៍ ដែលមានមូលដ្ឋាននៅតំបន់ Pioneer Square បានប្តូរទូររទេះ សំរាមនៅតាមច្រកផ្លូវរបស់ពួកគេ ជាមួយការប្រមូលយកជាញឹកញាប់នៃប្រព័ន្ធស្បោងសំរាមដែលបង់ឈ្នួលមុន នោះនាំផលឲ្យមានច្រកផ្លូវសាធារណៈ ស្អាតនិងមានសុវត្ថិភាព។ ប្រព័ន្ធស្បោងសំរាមដែលបានបង់ប្រាក់រួចនេះនឹងត្រូវប្រើដោយអាគារពាណិជ្ជកម្ម, អាគារជួល និងផ្ទះល្វែងខុនដូរ នៅក្នុងមណ្ឌលកំណត់សំរាប់ពាណិជ្ជកម្មចាប់តាំងពីថ្ងៃទី 30 ខែមិនា ឆ្នាំ 2009 តាមរយៈទូររទេះ សំរាមដែលបានធ្វើកិច្ចសន្យាសំរាប់ចោលសំរាម លើកលែងតែពួកគេមានកន្លែងសំរាប់ដាក់ធុងសំរាមនៅតាមកន្លែងឯកជន ឬជ្រើសយកការយកសំរាមទៅចោលដោយខ្លួនឯងនៅកន្លែងផ្ទេរសំរាមចោលរបស់ក្រុង។ ក្រុមហ៊ុនប្រមូលរបស់របរឆ្លៃឡើងវិញឯកជននិងក្រុមហ៊ុនកិច្ចសន្យានៃក្រុងគឺត្រូវផ្តល់ស្បោងដែលបង់ប្រាក់រួចសំរាប់ចោលរបស់របរឆ្លៃឡើងវិញនិងយកទៅធ្វើជី (ឧទាហរណ៍ ដូចជាកំទេចសំណល់អាហារ, ក្រដាសខ្ចប់អាហារ, កំទេចស្មៅកាត់) បើសិនជាម្ចាស់ផ្ទះគ្មានកន្លែងដាក់ធុងសំរាមដោយខ្លួនឯង ដូច្នេះរទេះសំរាមអាចត្រូវប្រើសំរាប់ដាក់របស់របរនានាដែលយោងទៅតាមការតំរូវនៅក្នុងជំពូកទី ៩ ។

**4.0 កម្មវិធី "ច្រកផ្លូវស្រឡះ" នៃតំបន់ចាត់តាំងពាណិជ្ជកម្ម:**

តំបន់ចាត់តាំងពាណិជ្ជកម្មគឺជាកន្លែងដែលបានចាត់តាំងដោយនាយក SPU សំរាប់បញ្ចូលក្នុងកម្មវិធី "ច្រកផ្លូវស្រឡះ" នៅពេលបច្ចុប្បន្ននិងអនាគត។ ក្នុងឆ្នាំ 2009 គេបញ្ចូលយ៉ាងតិច:

1) Downtown (ដោយរួមទាំង Belltown)
2) Pioneer Square

នៅពេលបន្ថែមមណ្ឌលចាត់តាំងពាណិជ្ជកម្មដែលបានជ្រើសយកដោយនាយក SPU អាចត្រូវបន្ថែមក្នុងឆ្នាំ 2009 បើភាគច្រើននៃអតិថិជនជំនួញនៅក្នុង តំបន់បានយល់ព្រម។ តំបន់ផ្សេងទៀតប្រហែលអាចត្រូវដាក់ក្នុងដំណាក់កាលរយៈឆ្នាំបន្តបន្ទាប់ក្រោយពីការអភិវឌ្ឍន៍មានការយល់ព្រមដំណើរការពី SPU។ មណ្ឌលចាត់តាំងពាណិជ្ជកម្មដែលគេបានបង្ហាញពីចំណូលចិត្តនៅក្នុងកម្មវិធី "ច្រកផ្លូវស្រឡះ" គឺ:

1) E. Olive/E. Union /Capitol Hill
2) មណ្ឌលអន្តរៈជាតិ
3) Lake Union ខាងត្បូង
4) Queen Anne ផ្សារលើ/ក្រោម
5) Fremont
6) មណ្ឌលសកលវិទ្យាល័យ
7) ផ្នែកខាងជើងបរិវេណសាលារៀន
8) ក្រុង Columbia
9) ទិសប្រសព្វខាងលិចក្រុង Seattle

**5.0 ចំនួនពេលវេលានៃការយកធុងរទេះសំរាមទៅដាក់និងយកមកវិញ "សមហេតុផល" មុននិងក្រោយពេលគេប្រមូល នៅតាមចិញ្ចើមថ្នល់ថ្មើជើង នឹងច្រកផ្លូវនៅតាមកន្លែង "ច្រកផ្លូវស្រឡះ" នៃមណ្ឌលចាត់តាំងពាណិជ្ជកម្ម:**

**ធុង, ធុងរទេះនិងទូររទេះ(ឬទូររទេះធំ):** ធុង, ធុងរទេះនឹងទូររទេះសំរាមរបស់ពលរដ្ឋឬហាងជំនួញសំរាប់ចោលសំរាម, សំណល់អាចផលិតឡើងវិញ ឬអាចធ្វើជី អាចត្រូវដាក់នៅលើចិញ្ចើមថ្នល់ឬតាមខាងច្រកផ្លូវសាធារណៈនៅវេលាម៉ោង 7 យប់ទៅដល់ 7 ព្រឹក ឬរហូតដល់ទៅ 3 ម៉ោងនៅមុនពេល កំណត់នៃការប្រមូលសំរាមរបស់ក្រុមហ៊ុនធ្វើកុងត្រាជាមួយសាលាក្រុង ឬអ្នកប្រមូលសំរាមឯកជន បើសិនជាគ្មានកន្លែងសំរាប់ដាក់ធុងនៅកន្លែងកម្មសិទ្ធិ ឯកជន។ ធុងទាំងនោះត្រូវយកមកវិញដោយអតិថិជននិងដាក់នៅក្នុងបរិវេណឯកជនរបស់គេនៅក្នុងរយៈពេល 3 ម៉ោងក្រោយពីប្រមូលសំរាមអស់។ ធុងស្មៅក៏អាចត្រូវដាក់រយៈពេល 3 ម៉ោងនៅមុនពេលគេកំណត់ប្រមូលដែរ។ នាយកចាត់តាំង SPU អាច បដិសេធទីកន្លែងដែលដាក់ធុងចោលពេញមួយយប់ឬពេញមួយថ្ងៃនៅថ្ងៃដែលគេប្រមូលដែរ។

គឺអាចគ្មានកន្លែងដាក់ធុង, ធុងរទេះនិងទូររទេះសំរាមជាអចិន្ត្រៃយ៍នៅលើចិញ្ចើមថ្នល់ថ្មើជើង និងរុក្ខវិថីថ្មើជើងឬនៅច្រកផ្លូវសាធារណៈទេ។

**6.0 ស្បោងសំរាមមានព៌ណខ្ចូដបង់ឈ្នួលជាមុនផ្សេងពីការប្រើទូររទេះ:**
អតិថិជនដែលជាពលរដ្ឋនិងហាងពាណិជ្ជកម្ម ដែលជ្រើសយកសេវាក្រុមហ៊ុន កុងត្រាជាមួយសាលាក្រុងនេះ នឹងត្រូវផ្តល់ស្បោងសំរាមមានព៌ណខ្ចូដដែលត្រូវបង់ឈ្នួលមុន និងកំណត់ពេលប្រមូលដោយអ្នកប្រមូលមានកុងត្រា "ជាមួយសាលាក្រុងរបស់ពួកគេសំរាប់ប្រមូល, សំរាមអាចធ្វើជី និងសំណល់អាចផលិតឡើងវិញ។ អតិថិជននឹងត្រូវយកស្បោងដែលបង់ឈ្នួលមុនទៅដាក់ឲ្យប្រមូលមិនឲ្យលើសពីបីម៉ោងនៅមុនពេលគេមកប្រមូលទេ។

ស្បោងនឹងត្រូវមានពណ៌ខ្ចូដ ដោយសំអាងទៅលើប្រភេទនៃសំរាមឬសម្ភារៈដែលត្រូវប្រមូល។ អ្នកប្រមូលសំរាមឯកជនសំរាប់សំណល់ផលិតឡើងវិញ អាចជ្រើសយកការផ្តល់សេវាផ្នែកស្បោងប្រហែលគ្នាទៅឲ្យអតិថិជន និងត្រូវផ្តល់ឲ្យអតិថិជនទូវតារាងម៉ោងពេលប្រមូលសំរាម។ អតិថិជននឹងត្រូវយកស្បោងទៅដាក់សំរាប់ឲ្យប្រមូលមិនឲ្យលើសពីបីម៉ោងនៅមុនម៉ោងកំណត់ត្រូវប្រមូលទេ។

**7.0 ការដកហូតធុងទូររទេះសំរាមនៅ "ច្រកផ្លូវស្រឡះ": នៃមណ្ឌលចាត់តាំងពាណិជ្ជកម្ម:**
ធុងរទេះសំរាមនៅកណ្តាល Downtown និងនៅមណ្ឌលចាត់តាំងពាណិជ្ជកម្មដែលមិនអាចយកទៅទុកនៅកន្លែង ROW នឹងត្រូវដកហូតចេញនៅរវាងថ្ងៃ 3/30/09 និង 4/30/09 ។ អតិថិជនដែល គ្មានកន្លែងណាក្រៅពី ROW សំរាប់ដាក់រទេះឬទូររទេះសំរាមរបស់គេ នឹងត្រូវប្រើស្បោងដែលបង់ឈ្នួលមុនចាប់ពីថ្ងៃ 3/30/09 ។

**8.0 ព្រំប្រទល់ប្រមូលសំរាមនៃមណ្ឌលចាត់តាំងពាណិជ្ជកម្មក្នុងឆ្នាំ 2009**

1) **Downtown:** ព្រំប្រទល់មណ្ឌលចាត់តាំងពាណិជ្ជកម្មនៅ Downtown គឺ Eliot Bay នៅទិសខាងលិច, Bay Street រហូតទៅដល់ Denny Way នៅទិសខាងជើង(នៅខាងត្បូងនៃផ្លូវទាំងនោះ)។ ផ្លូវឆ្លងកាត់រដ្ឋ I-5 នៅទិសខាងកើត(នៅខាងលិចនៃផ្លូវជាតិ) និង Yesler Way នៅខាងត្បូង(នៅខាងជើងនៃផ្លូវ roadway) ។ ចូរមើលផែនទីភ្ជាប់ជាមួយនៃតំបន់ "Downtown" សំរាប់ផ្លូវទាំងអស់ដែលរួមបញ្ចូលហើយនិងច្រកផ្លូវ។ ផ្លូវឯកជន, ច្រកផ្លូវនិងផ្លូវខណ្ឌមិននៅក្រោមបទបញ្ញត្តិនេះទេ។

2) **Pioneer Square:** ព្រំប្រទល់នៃតំបន់កំណត់សំរាប់មណ្ឌលពាណិជ្ជកម្ម Pioneer Square គឺតំបន់ Elliot Bay ទៅទិសខាងលិច, ផ្លូវ Yesler Way ទៅទិសខាងជើង (ជ្រុងខាងត្បូងនៃផ្លូវ), ផ្លូវ 4th Avenue S. ទៅទិសខាងកើត (ជ្រុងខាងលិចនៃផ្លូវរទេះភ្លើង) ទៅដល់ផ្លូវ S. King Street ទៅទិសខាងត្បូងនិងរួចហើយទៅខាងលិចតាមដងផ្លូវ S. King Street ទៅផ្លូវ Occidental Avenue S. (ជ្រុងខាងលិចនៃផ្លូវរទេះភ្លើង)។ នៅតាមព្រំខាងកើត រួចហើយទៅជាផ្លូវ Occidental Avenue S (ជ្រុងខាងលិចនៃផ្លូវរទេះភ្លើង) ទិសខាងត្បូងទៅផ្លូវ South Royal Brougham Way (ជ្រុងខាងជើងនៃផ្លូវរទេះភ្លើង)។ ចាប់តាំងពីព្រំខាងត្បូងនៃផ្លូវ South Royal Brougham Way, ព្រំខាងលិចបន្តទៅផ្លូវ 1st Avenue S. ទិសខាងជើងរហូតដល់ផ្លូវ Railroad Way S. រួចហើយទៅដល់ផ្លូវ Alaska Way South ទិសខាងជើងទៅដល់ផ្លូវ S. King Street។ ចូរមើលផែនទីដែលភ្ជាប់មក ជាមួយនៃ "តំបន់ផ្សារធំ" ("Downtown Area") សំរាប់គ្រប់អ្វីទាំងអស់នៃផ្លូវនិងច្រកផ្លូវដែលបាន ដាក់បញ្ចូល។ ផ្លូវឯកជន, ច្រកផ្លូវ និងផែសំណង់គឺមិននៅក្រោមច្បាប់នេះទេ។

**9.0 ការរួចផុតពីច្បាប់នៅក្នុងតំបន់កំណត់សំរាប់ពាណិជ្ជកម្មសំរាប់កម្មវិធីច្រកផ្លូវស្រឡះ :**
ប្រភេទនៃធុងនិងសម្ភារៈដូចតទៅនេះគឺត្រូវរួចផុតពីច្បាប់នេះដោយមានលក្ខណៈនានាជាក់ច្បាស់:

1) ធុងសំរាប់ដាក់ប្រេងចំអិនអាហារដែលប្រើរួច ដែលជួបតាមការតំរូវសុខភាពសាធារណៈនិងបរិស្ថាន គឺរួចផុតពីច្បាប់ពិតប្រាកដ។

2) រទេះដែលមានផ្លាកចំណុះ (32, 60 ឬ 96 ហ្គាឡុង) មានគំរបដែលបិទយ៉ាងជិត សំរាប់ដាក់កំទេចសំណល់អាហារ/ក្រដាសខ្ចប់អាហារ, កំទេចស្មៅកាត់ បើសិនជាគ្មានកន្លែងដាក់ធុងនៅតាមកន្លែងឯកជន

ដែលអាចបញ្ឆាក់ដោយក្រុងបាន។ ស្បោងសំរាមដែលបង់ប្រាក់មុនបានប្រើសំរាប់ប្រមូលសំរាមគ្មានធាតុគីមី ត្រូវតែមានការយល់ព្រមពីក្រុមហ៊ុនទឹកភ្លើងសាធារណៈនៃក្រុង Seattle ។

3) រទេះដែលមានផ្លាកចំណុះ (32, 60 ឬ 96 ហ្គាឡុង) សំរាប់ដាក់កញ្ចក់ បើសិនជាគ្មានកន្លែងដាក់ធុងនៅតាមកន្លែងឯកជន ដែលអាចបញ្ឆាក់ដោយក្រុងបាន។

4) រទេះដែលមានផ្លាកចំណុះ (32, 60 ឬ 96 ហ្គាឡុង) សំរាប់លាមកសត្វ បើសិនជាគ្មានកន្លែងដាក់ធុងនៅតាមកន្លែងឯកជន ដែលអាចបញ្ឆាក់ដោយក្រុងបាន។

អតិថិជនដែលចង់ទទួលបានការរួចខ្លួនសំរាប់រទេះសំរាមសំរាប់ចោលរបស់គ្មានធាតុគីមី, កញ្ចក់ និងលាមកសត្វ ហើយនិងចង់ទុកចោលរយៈពេលយូរនៅតាមច្រកផ្លូវសាធារណៈ ត្រូវតែទាក់ទងទៅក្រុមហ៊ុនទឹកភ្លើងសាធារណៈនៃក្រុង Seattle ដើម្បីឲ្យមានការត្រួតពិនិត្យតាមបរិវេណឯកជនដែលខ្វះកន្លែងសំរាប់ដាក់ធុង។

**10.0 ថ្ងៃសុពលភាពនៃបទបញ្ញត្តិ:**
ថ្ងៃសុពលភាពសំរាប់បទបញ្ញត្តិនេះគឺនៅពេលដាក់បណ្តឹងជាមួយនឹងស្មៀនសារការីសាលាក្រុង Seattle ។